# សំណួរដែលបានសួរជាញឹកញាប់អំពី
# ច្បាប់ហាមឃាត់ការរើសអើងជនជាតិអាមេរិកដែលមានពិការភាព (ADA) និងដំណើរការនៃការដាក់ពាក្យបណ្ដឹងអំពីការមិនពេញចិត្ត ចំពោះការមិនអាចទទួលបានជំនួយផ្នែកភាសា

## តើដំណើរការនៃការដាក់ពាក្យបណ្ដឹងអំពីការមិនពេញចិត្តនេះគឺដើម្បីគោលបំណងអ្វី?

ដំណើរការនេះគឺបានបង្កើតឡើងដើម្បីប្រមូលយកព័ត៌មានដែលចាំបាច់សម្រាប់ដោះស្រាយពាក្យបណ្ដឹងអំពីការមិនពេញចិត្តផ្សេងៗទាក់ទងទៅនឹងការបំពានផ្នែកច្បាប់ហាមឃាត់ការរើសអើងជនជាតិអាមេរិកដែលមានពិការភាព (Americans with Disabilities Act/ADA) និងសេវាកម្មចំពោះការទទួលបានជំនួយផ្នែកភាសា (Language Access Services) ដែលបានចោទប្រកាន់ថាកើតមាននៅក្នុងនាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (Los Angeles County Department of Public Health)។ ដំណើរការនេះនឹងជួយដល់នាយកដ្ឋានសុខភាពសាធារណៈកែលម្អដល់សេវាកម្មផ្សេងៗ និងធានាថាមនុស្សគ្រប់រូបអាចទទួលបានសេវាកម្មផ្សេងៗដែលពួកគេត្រូវការ។

## តើពាក្យបណ្ដឹងអំពីការមិនពេញចិត្តមួយគួរតែដាក់នៅពេលណា?

អតិថិជនរបស់នាយកដ្ឋានសុខភាពសាធារណៈគួរតែដាក់ពាក្យបណ្ដឹងអំពីការមិនពេញចិត្តនៅពេលណាក៏ដោយដែលពួកគេមានអារម្មណ៍ថាពួកគេមិនបានទទួលការសម្របសម្រួលនានាដោយយោងទៅតាមច្បាប់ហាមឃាត់ការរើសអើងជនជាតិអាមេរិកដែលមានពិការភាព ឬសេវាកម្មចំពោះការទទួលបានជំនួយផ្នែកភាសាដែលត្រឹមត្រូវ។ បែបបទនេះគឺសម្រាប់ការបំពានដែលបានចោទប្រកាន់ថាកើតឡើងនៅក្នុងអគាររបស់នាយកដ្ឋានសុខភាពសាធារណៈ កើតឡើងជាផ្នែកមួយនៃកម្មវិធីឬសេវាកម្មមួយរបស់នាយកដ្ឋានសុខភាពសាធារណៈ ឬក៏កើតឡើងជាមួយនឹងសមាជិកក្រុមការងារឬដៃគូធ្វើកិច្ចការម្នាក់របស់នាយកដ្ឋានសុខភាពសាធារណៈ។

## តើការដាក់ពាក្យបណ្ដឹងអំពីការមិនពេញចិត្តនេះមានដំណើរការយ៉ាងដូចម្ដេចខ្លះ?

1. ចូលទៅកាន់គេហទំព័រ http://publichealth.lacounty.gov/ADA.htm ដើម្បីទទួលបានបែបបទទាំងអស់ និងធនធានផ្សេងៗ។
   *គេហទំព័រនេះក៏អាចចូលទៅដល់ផងដែរ តាមរយៈតំណភ្ជាប់៖*
   *http://publichealth.lacounty.gov/language/index.htm*

2. ប្រើប្រាស់តំណភ្ជាប់ទៅកាន់គេហទំព័រដើមខាងក្រោមនេះសម្រាប់ភាសាទាំងនេះ៖
   
   សម្រាប់ភាសាអង់គ្លេស ចិនបុរាណ ហ្វាស៊ី ជប៉ុន ខ្មែរ កូរ៉េ រុស្ស៊ី អេស្ប៉ាញ តាហ្គាឡុក ថៃ និងវៀតណាម៖
   https://forms.cloud.microsoft/g/GgTxT2msGk
   
   សម្រាប់ភាសាអារ៉ាប់ អាមីនៀន និងចិនសាមញ្ញ៖
   https://forms.cloud.microsoft/g/b35xiwtbcz

(Cambodian)

សូមកត់សម្គាល់ថាបែបបទជាភាសាអាមីនៀនគឺបានដាក់នៅក្នុងបញ្ជីថាជាភាសាអង់គ្លេស ប៉ុន្តែខ្លឹមសារបែបបទនេះគឺជាភាសាអាមីនៀន។

3. នៅពេលដែលបានដាក់បញ្ជូនព័ត៌មានទាំងអស់ហើយនោះ នាយកដ្ឋានសុខភាពសាធារណៈនឹងទទួលស្គាល់ថាបានទទួលពាក្យបណ្ដឹងអំពីការមិនពេញចិត្តរបស់អ្នក ដោយផ្ញើជាលិខិតមួយទៅអ្នក ក្នុងអំឡុងពេលប្រាំ (5) ថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ) បន្ទាប់ពីថ្ងៃដែលអ្នកបានដាក់ពាក្យបណ្ដឹងនោះ។

4. នាយកដ្ឋានសុខភាពសាធារណៈនឹងដោះស្រាយពាក្យបណ្ដឹងអំពីការមិនពេញចិត្តទាំងអស់ឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។ ចំពោះពាក្យបណ្ដឹងអំពីការមិនពេញចិត្តចំពោះការមិនអាចទទួលបានជំនួយផ្នែកភាសា (Language Access Complaints) ផ្សេងៗ នាយកដ្ឋានសុខភាពសាធារណៈនឹងដោះស្រាយជូនមិនឱ្យលើសពីចំនួន 90 ថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ) បន្ទាប់ពីថ្ងៃដែលយើងខ្ញុំទទួលបានពាក្យបណ្ដឹងរបស់អ្នក។

   យើងខ្ញុំនឹងដោះស្រាយពាក្យបណ្ដឹងអំពីការមិនពេញចិត្តទាំងឡាយទាក់ទងទៅនឹងច្បាប់ហាមឃាត់ការរើសអើងជនជាតិអាមេរិកដែលមានពិការភាពឱ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន និងមិនឱ្យលើសពីចំនួន 90 ថ្ងៃធ្វើការ (មិនគិតថ្ងៃសៅរ៍ និងថ្ងៃអាទិត្យទេ) បន្ទាប់ពីថ្ងៃដែលបានទទួលពាក្យបណ្ដឹងនោះ។ ប្រសិនបើការកែប្រែដែលបានស្នើសុំឱ្យអនុវត្តនោះត្រូវការឱ្យមានការចំណាយក្នុងកម្រិតគួរឱ្យកត់សម្គាល់ ឬមានការផ្លាស់ប្ដូរដល់លំនាំការងារនោះ នាយកដ្ឋានសុខភាពសាធារណៈនឹងវិភាគអំពីលទ្ធភាពដែលអាចធ្វើបាន និងស្វែងរកដំណោះស្រាយផ្សេងទៀត ដើម្បីធានាថាអាចទទួលបានសេវាកម្មផ្សេងៗ ហើយដោយមានការពិចារណាអំពីធនធានផ្សេងៗដែលមាន ផងដែរ។

## ចុះប្រសិនបើខ្ញុំមានសំណួរអំពីដំណើរការនេះវិញ?

ចំពោះសំណួរណាមួយ ឬដើម្បីពិនិត្យមើលស្ថានភាពរបស់ពាក្យបណ្ដឹងអំពីការមិនពេញចិត្ត ឬក៏ដើម្បីស្នើសុំការជួបប្រជុំក្រៅផ្លូវការមួយសម្រាប់ពិភាក្សាអំពីការព្រួយបារម្ភផ្សេងៗទាក់ទងទៅនឹងច្បាប់ហាមឃាត់ការរើសអើងជនជាតិអាមេរិកដែលមានពិការភាព (ADA) និងជំនួយផ្នែកភាសារបស់នាយកដ្ឋាន សូមទាក់ទងទៅកាន់អ្នកសម្របសម្រួលផ្នែកការគោរពដល់ ADA របស់នាយកដ្ឋានសុខភាពសាធារណៈតាមរយៈព័ត៌មានទំនាក់ទំនងខាងក្រោមនេះ៖

**អ្នកសម្របសម្រួលផ្នែកការគោរពដល់ ADA (ADA Compliance Coordinator)**
លេខទូរស័ព្ទ៖ (844) 914-1006
លេខសម្រាប់អ្នកថ្លង់ (TTY)៖ (800) 897-0077
អ៊ីម៉េល៖ DPH-ADA@ph.lacounty.gov

**ចុះប្រសិនបើខ្ញុំចង់ដាក់បញ្ជូនពាក្យបណ្ដឹងអំពីការមិនពេញចិត្តរបស់ខ្ញុំទៅអង្គភាពផ្សេងក្រៅពីនាយកដ្ឋានសុខភាពសាធារណៈដាង?**
អ្នកក៏អាចនឹងជ្រើសរើសទាក់ទងទៅកាន់ការិយាល័យនាយកប្រតិបត្តិនៃផ្នែកសិទ្ធិរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹងពិការភាព (CEO, Disability Civil Rights Section) តាមរយៈ៖

Chief Executive Office, Disability Civil Rights Section
500 West Temple Street, Room 754, Los Angeles, California 90012
លេខទូរស័ព្ទ៖ (213) 202-6944
លេខសម្រាប់អ្នកថ្លង់៖ (855) 872-0443
អ៊ីម៉េល៖ Adavis@ceo.lacounty.gov

ការិយាល័យនាយកប្រតិបត្តិនឹងសហការជាមួយអ្នកដោយផ្ទាល់ ដើម្បីឆ្លើយតបទៅនឹងពាក្យបណ្ដឹងអំពីការមិនពេញចិត្តរបស់អ្នក។

**សូមកត់សម្គាល់ថា៖**

- ការប្រើប្រាស់ដំណើរការក្រៅផ្លូវការនៃការដាក់ពាក្យបណ្ដឹងអំពីការមិនពេញចិត្តនេះគឺមិនមែនជាតម្រូវការចាំបាច់ដែលត្រូវតែអនុវត្តនោះទេ ហើយក៏មិនរារាំងអ្នកពីការដាក់ពាក្យបណ្ដឹងអំពីការមិនពេញចិត្តជាមួយនឹងទីភ្នាក់ងារផ្នែកអនុវត្តច្បាប់ដែលត្រឹមត្រូវនោះដែរ។
- ការសងសឹក ការបង្ខិតបង្ខំ ការបំភិតបំភ័យ ការគំរាមកំហែង ការរំខាន ឬការបៀតបៀនណាមួយចំពោះការដាក់ពាក្យបណ្ដឹងអំពីការមិនពេញចិត្តគឺជាការហាមឃាត់ ហើយអ្នកគួរតែរាយការណ៍ឱ្យបានភ្លាមៗទៅកាន់អ្នកសម្របសម្រួលផ្នែកការគោរពដល់ ADA របស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health ADA Compliance Coordinator) តាមរយៈលេខ៖ (844) 914-1006 ឬក៏រាយការណ៍ឱ្យបានភ្លាមៗទៅកាន់ការិយាល័យប្រធានប្រតិបត្តិនៃផ្នែកសិទ្ធិរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹងពិការភាពរបស់ខោនធី (County's Chief Executive Office, Disability Civil Rights Section) តាមរយៈលេខ៖ (213) 202-6944។